អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ភ្នំពេញថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩

# សេចក្តីប្រកាសព័ត៌មាន,

ចៅក្រមជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានការសោកស្តាយយ៉ាងខ្លាំងនៅពេលទទួលបាននូវដំណឹងតាមសារព័ត៌មាននានានៅថ្ងៃនេះថា លោកសហមេធាវី មីសែល ផេសមិន និងលោក វីកទ័រ កូប៉េ និងអ្នកជំនួយរបស់គាត់គឺ លោក អែនទ្រូ អ៊ីយ៉ានូហ្សី បានដាក់ពាក្យប្តឹងទៅតុលាការក្រុងភ្នំពេញដោយចោទប្រកាន់អំពីអំពើពុករលួយនៅក្នុងតុលាការខ្មែរក្រហមនេះដែលអាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងថាមានចៅក្រមជាតិបានកាត់ប្រាក់បៀវត្សន៍របស់ខ្លួនមួយផ្នែកឲ្យទៅមន្ត្រីរដ្ឋាភិបាលសម្រាប់ជាថ្នូរការងារនៅតុលាការនេះ។

សកម្មភាពនៃហេតុការណ៍ខាងលើនេះ ត្រូវបានទម្លាយចេញទៅប្រព័ន្ធផ្សព្វផ្សាយទូទៅជាសាធារណៈធ្វើឲ្យសាធារណជនមានការភាន់ច្រឡំ គឺធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និង សេចក្តីថ្លៃថ្នូរយ៉ាងធ្ងន់ធ្ងរបំផុតដល់បុគ្គលចៅក្រមទាំងអស់ផង និង ស្ថាប័ននេះទាំងមូលផង។ យើងសូមជម្រាបថា ចៅក្រមទាំងអស់ដែលបានចូលមកបំរើការងារនៅតុលាការនេះ គឺតាមការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាជាប្រធានបានឡាយព្រះហត្ថលេខាលើព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២១៤ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៦ តែងតាំងយើងទាំងអស់គ្នាឲ្យមកបំពេញការងារនៅតុលាការនេះ ។ ដូច្នេះមិនមានហេតុផលអ្វីដែលចៅក្រមត្រូវកាត់ប្រាក់បៀវត្សន៍មួយផ្នែកឲ្យទៅមន្ត្រីរដ្ឋាភិបាលដូចការចោទប្រកាន់នោះទេ។ យើងសូមបដិសេធការចោទប្រកាន់នេះទាំងស្រុង។

យើងសូមជម្រាបជាចុងក្រោយថាប្រសិនបើសកម្មភាពចោទប្រកាន់ខាងលើនេះបានធ្វើឡើងដោយអសុទ្ធចិត្តទម្លាក់កំហុសលើចៅក្រមនោះ យើងសូមរក្សាសិទ្ធិការពារតាមផ្លូវច្បាប់ចំពោះបុគ្គលដែលបានបង្កឲ្យមាននូវបញ្ហានេះ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh